ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

៧៣
ថ

តុលាការកំពូល

# សាលដីកា

សំណុំរឿងរដ្ឋប្បវេណី
លេខ : ១៧០
ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៣
សាលដីកា
លេខ : ១៨០ "ឈ"
ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ជាសាធារណៈ
នៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤ ដោយមានសមាសភាពដូចតទៅ ៖

-ឯកឧត្តម [redacted] ជាប្រធាន
-លោក ជាចៅក្រម
-លោក ជាចៅក្រម
-លោក ជាចៅក្រម
-លោក ជាចៅក្រម
-លោក ជាក្រឡាបញ្ជី

តំណាងមហាអយ្យការ
-លោក [redacted] ជាព្រះរាជអាជ្ញា

លើបណ្តឹងសាទុក្ខ ពីសាលដីការដ្ឋប្បវេណីលេខ ២០ "ក្រVIអ" ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ ២០១៣ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ២៤៨ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ រវាង ៖

-ដើមចោទ :

១-ឈ្មោះ [redacted] ដាត (ចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤៩ឆ្នាំ លំនៅដ្ឋានសព្វថ្ងៃភូមិជ័យជំនះ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ប្រពន្ធឈ្មោះ [redacted] សំ មានកូន ៣ នាក់។

២-ឈ្មោះ [redacted] ហ្សាក់ (ចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៤១ឆ្នាំ លំនៅដ្ឋានសព្វថ្ងៃភូមិ ៣ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី។

៣-ឈ្មោះ [redacted] រ៉ានី (ចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ៣៣ឆ្នាំ លំនៅដ្ឋានសព្វថ្ងៃភូមិ ៣ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី។



មហាវិថី សម្តេចសុធារស, សង្កាត់ចតុមុខ, ខណ្ឌដូនពេញ, កម្ពុជា Sothearos Blvd, Sangkat Chatomuk, Khan Daun Penh, Cambodia

Scanned with CamScanner

៤-ឈ្មោះ [redacted] នូរី (ចុងបណ្តឹងសាទុក្ខ) ភេទប្រុស អាយុ២៥ឆ្នាំ លំនៅដ្ឋានសព្វថ្ងៃភូមិ ១ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី (នៅលីវ)។

.មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ

-<u>ចុងចម្លើយ</u> : ឈ្មោះ [redacted] រ៉ីម៉ាស់ "ហៅផុ" (ម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៥៦ឆ្នាំ លំនៅដ្ឋានសព្វថ្ងៃភូមិ ៣ សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ប្តីឈ្មោះ [redacted] ឡេះ "ស" មានកូន ៤ នាក់។

.មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ

<u>កម្មវត្ថុបណ្តឹង</u> : ទាមទារបែងចែកមរតកដីទំហំ ២៧ ម x ៦៨ ម ស្ថិតនៅភូមិ ៣ សង្កាត់ ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ។

-តាមបណ្តឹងសាទុក្ខលេខ ១៤៦ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] រ៉ីម៉ាស់ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ២០ "ក្រVIអ" ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៧០ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៣ របស់តុលាការកំពូល។

-ដើមចោទប្តឹងសុំអោយតុលាការចេញសាលក្រមបង្គាប់អោយចុងចម្លើយឈ្មោះ [redacted] រ៉ីម៉ាស់ បែងចែកមរតករបស់សពឪពុកឈ្មោះ [redacted] ឡេះ នូវដីទំហំ ២៧ ម x ៦៨ ម ដែលមានសំណង់ផ្ទះ និងសំណង់បន្ទប់ជួលចំនួន ២៣ បន្ទប់ ស្ថិតនៅភូមិ ៧ មករា (អតីតភូមិ ៣) សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី។

-បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ០១ "ខ" ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ របស់សាលាដំបូងខេត្តរតនគិរី ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលពាក្យបណ្តឹង ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២ របស់សហដើមចោទឈ្មោះ [redacted] ដាត ,ឈ្មោះ [redacted] ហ្សាកី ,ឈ្មោះ [redacted] រ៉ានី និងឈ្មោះ [redacted] នូរី ធ្វើឡើងតាមកំណត់ច្បាប់ ត្រង់មាត្រា ៧៥ ,១២ ,៧០ ក្រមនីតិវិធីរដ្ឋប្បវេណី។

២-ប្រគល់មតិក (ដីទំហំ ១.៨០៣ ម² មានសំណង់ផ្ទះទំហំ ១៣៨ ម² មានសំណង់ផ្ទះល្វែងសង់ជាបន្ទប់ៗសរុបចំនួន ២៣ បន្ទប់) នៅភូមិ ៧ មករា សង្កាត់ឡាបានសៀក ក្រុងបានលុង ខេត្តរតនគិរី ឱ្យទៅឈ្មោះ [redacted] រ៉ីម៉ាស់ ចំនួនពាក់កណ្តាលនៃមតិក នៅសល់មតិកពាក់កណ្តាលទៀត







Scanned with CamScanner

ប្រគល់ឲ្យសន្តតិជនឈ្មោះ [redacted] ដាត ភេទប្រុស អាយុ៤៩ឆ្នាំ ,ឈ្មោះ [redacted] ហ្សាគី ភេទប្រុស អាយុ ៤១ឆ្នាំ ,ឈ្មោះ [redacted] វ៉ន់ទី ភេទប្រុស អាយុ៣៣ឆ្នាំ ,ឈ្មោះ [redacted] ទូរី ភេទប្រុស អាយុ២៥ឆ្នាំ ,ឈ្មោះ [redacted] សេងហុង ភេទប្រុស អាយុ២៨ឆ្នាំ ,ឈ្មោះ [redacted] វ៉ូស្រាក់ ភេទប្រុស អាយុ២៦ឆ្នាំ ,ឈ្មោះ [redacted] ឧសភា ភេទប្រុស អាយុ១៦ឆ្នាំ និងឈ្មោះ [redacted] ធារី ភេទស្រី អាយុ១២ឆ្នាំ ព្រមទាំងប្រពន្ធឈ្មោះ [redacted] រ៉ម៉ាស មានចំណែកស្មើៗគ្នា គិតចាប់ពីសាលក្រមចូលជាស្ថាពរ តាមមាត្រា ១២៦៧ , ១២៦៨ ក្រមរដ្ឋប្បវេណី។

៣-ប្រដាប់ក្តីជាបន្ទុកលើដើមចោទ។

សាលក្រមនេះ បានទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២ និងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ និងប្រកាសជាសាធារណៈនៅសាលសវនាការនៃសាលាដំបូងខេត្តរតនគិរី នូវចំពោះមុខដើមចោទ និងចុងចម្លើយ នាថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣។

បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ០៦ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] រ៉ម៉ាស់ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ០១ “ខ” ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ របស់សាលាដំបូងខេត្តរតនគិរី ត្រង់ចំណុចសាលក្រមទាំងមូល។

-បានឃើញសាលដីការដ្ឋប្បវេណីលេខ ២០ “ក្រIVអ” ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ ៖

១-ច្រានចោលបណ្តឹងឧទ្ធរណ៍លេខ ០៦ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] រ៉ម៉ាស់។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ០១ “ខ” ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ របស់សាលាដំបូងខេត្តរតនគិរី ទុកជាបានការ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុកចុងចម្លើយ។

៤-សាលដីកានេះ បញ្ចប់ការទាញហេតុផលផ្ទាល់មាត់ និងប្រកាសជាសាធារណៈ បើកសិទ្ធិប្តឹងសាទុក្ខរយៈពេល ១ ខែ គិតពីថ្ងៃបានទទួលការបញ្ជូនសាលដីកានេះ។

-បានឃើញបណ្តឹងសាទុក្ខលេខ ១៤៦ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] រ៉ម៉ាស់ ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ ២០ “ក្រVIអ” ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសាលដីកាទាំងមូល។

-បានឃើញលិខិតបញ្ជាក់ពីមូលហេតុបណ្តឹងសាទុក្ខ របស់លោក [redacted] មេធាវី តំណាងដោយអាណត្តិឱ្យម្ចាស់បណ្តឹងសាទុក្ខឈ្មោះ [redacted] ម៉ាស់។

-បានឃើញឯកសារគ្រៀម (សារណាតប) របស់ចុងបណ្តឹងសាទុក្ខឈ្មោះ [redacted] ដាត , ឈ្មោះ [redacted] ហ្វាក់ ,ឈ្មោះ [redacted] រ៉នី ,ឈ្មោះ [redacted] ធូរី។

-បានស្តាប់របាយការណ៍របស់ចៅក្រមទទួលបញ្ជា

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សំណុំរឿងនេះជាការប្តឹងសុំបែងចែក មរតក ជាវិវាទគ្រួសារ មិនប៉ះពាល់ប្រយោជន៍សាធារណៈទេ ប៉ុន្តែពិចារណាលើបំណុលដែលតុលាការ ថ្នាក់ក្រោមពុំទាន់បានពិចារណាទេ សូមសំរេចចុះ។

## ដំណាក់កាលទាញហេតុផលផ្ទាល់មាត់

-បានស្តាប់ក្រឡាបញ្ជីអានលិខិតបញ្ជាក់ពីមូលហេតុបណ្តឹងសាទុក្ខរបស់ម្ចាស់បណ្តឹងសាទុក្ខ។

-លោក [redacted] ហ្វាក់ ជាចុងបណ្តឹងសាទុក្ខ បានធ្វើសេចក្តីថ្លែងការណ៍ថា ៖

ខ្លួននិយាយក្នុងពេលនេះ ក្នុងនាមតំណាងឱ្យដើមចោទទាំងអស់ បំណុលឪពុកខ្លួនមិនបាន ជំពាក់នរណាទេ សូម្បីគាត់ជំពាក់ ACELEDA ឪពុកប្រាប់ខ្លួន ឯបំណុលក្រោយៗទៀត គ្មានទេ ខ្ចីធនាគារ គឺខ្ចីបង្វិលដី មិនមែនយកធ្វើផ្ទះជួលទេ ដំណាំកៅស៊ូ ឪពុកខ្លួនទិញដីហើយដាំកៅស៊ូ ក្រោយបង្វិលវិញអស់ហើយ គ្មានខ្ចីនរណាផ្សេងទេ។ នៅពេលឪពុកឈឺ មានការដឹកមកព្យាបាល នៅមន្ទីរពេទ្យមែន។

-លោក [redacted] មេធាវីតំណាងដោយអាណត្តិឱ្យម្ចាស់បណ្តឹងសាទុក្ខ បានធ្វើសេចក្តី សន្និដ្ឋានថា ៖

រឿងនេះ សាលាឧទ្ធរណ៍ ក៏ដូចជាតុលាការខេត្តរតនគិរី សំរេចមិនត្រឹមត្រូវទេ ពីព្រោះមិន បានពិចារណាលើបំណុលដែលបានជំពាក់គេក្នុងពេលរកស៊ី មុនពេលទទួលមរណភាព ពិសេសគួរ ពិចារណាលើទ្រព្យសកម្ម និងទ្រព្យអកម្ម មុននឹងធ្វើការបែងចែកទ្រព្យមរតកអោយសន្តិជន ម្យ៉ាង មានសមាជិកខ្លះមិនទាំងបានប្តឹងទារផង បែងជាតុលាការបែងចែកដែរ នេះជាការសំរេចផ្ទុយពីច្បាប់។ មានឯកសារទាំងអស់ពាក់ព័ន្ធនឹងការខ្ចីបំណុលគេក្នុងការរកស៊ីផង ខ្ចីគេដើម្បីព្យាបាលជំងឺអោយប្តី។ កិច្ចសន្យាខ្ចីពីធនាគារ ACELEDA ក៏មានខ្ចីពីរូបវន្តបុគ្គល ក៏មានដូចមានក្នុងសំណុំរឿងស្រាប់ បើធ្វើ ការទូទាត់ទៅ បំណុលលើសពីដី និងផ្ទះជួលជាមរតកត្រូវបែងចែកទៅទៀត។ ការបែងចែកមរតក ឱ្យដើមចោទ ប៉ះពាល់លើបំណុល។ សុំបង្វិលឱ្យសាលាឧទ្ធរណ៍ពិចារណាលើបំណុល និងបដិសេធ សាលដីកាសាលាឧទ្ធរណ៍។

-លោក [redacted] មេធាវីតំណាងដោយអាណត្តិឱ្យចុងបណ្តឹងសាទុក្ខ បានធ្វើសេចក្តីសន្និដ្ឋានថា ៖

អង្គហេតុរឿងនេះ ដើមចោទបានលើកជូនក្នុងមូលហេតុបណ្តឹងសាទុក្ខហើយ ខ្លួនសុំមិនលើកឡើងច្រើនទេ សូមធ្វើសេចក្តីសន្និដ្ឋានដូចតទៅ។ ក្រោយប្តីចុងចម្លើយស្លាប់ សល់ដី និងផ្ទះជួល ២៣ បន្ទប់ ដើមចោទសុំឱ្យបែងចែកមរតករបស់ឪពុក តែចុងចម្លើយលោភលន់ មិនចង់បែងចែកទេ បែជារកលេសថា ជំពាក់បំណុល។ ការបែងចែកទ្រព្យមរតករបស់តុលាការថ្នាក់ក្រោមសមរម្យហើយ ចុងចម្លើយក៏បានចំណែកច្រើនដែរ ហេតុអ្វីចុងចម្លើយនៅតែលោភលន់ប្តឹងបន្តរហូត។ ការសំរេចសេចក្តីរបស់សាលាដំបូង និងសាលាឧទ្ធរណ៍ សំរេចត្រឹមត្រូវហើយ។ អំពីបំណុលសួរថា បំណុលនេះមានការទទួលស្គាល់ពីសហព័ន្ធទេ ហើយឯកសារពាក់ព័ន្ធ ម្តេចមិនដាក់ពីសាលាដំបូង ទើបដាក់ថ្មីផ្ទុយពីមាត្រា ១០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ភស្តុតាងអំពីបំណុលនេះ សុំបដិសេធចោល និងសុំតម្កល់សាលដីកាសាលាឧទ្ធរណ៍ទុកបានការ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សេចក្តីថ្លែងការណ៍របស់ដើមចោទ និងមេធាវីតំណាងដោយអាណត្តិរបស់គូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ ។

## តុលាការកំពូល

-យល់ឃើញថា : បណ្តឹងសាទុក្ខលេខ ១៤៦ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៣ របស់ចុងចម្លើយឈ្មោះ [redacted] វ៉ីម៉ាស់ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា ២៨៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

-យល់ឃើញថា : ការដែលសាលាឧទ្ធរណ៍សម្រេចតម្កល់សាលក្រមរបស់សាលាដំបូងខេត្តរតនគិរី ទុកជាបានការ ដោយបែងចែកទ្រព្យមរតកចំនួនពាក់កណ្តាលអោយទៅចុងចម្លើយ ហើយចំនួនពាក់កណ្តាលទៀតអោយទៅសន្តតិជនចំនួន ៩ នាក់ រួមទាំងចុងចម្លើយផង ក្នុងចំណែកស្មើៗនោះ មិនទាន់មានមូលដ្ឋានគ្រប់គ្រាន់នៅឡើយទេ ព្រោះថា ការបែងចែកមរតករបស់សាលាដំបូងខេត្តរតនគិរី និងសាលាឧទ្ធរណ៍ បានពិចារណាតែលើទ្រព្យសកម្មរបស់មតកជនប៉ុណ្ណោះ ចំណែកទ្រព្យអកម្ម និងការចំណាយផ្សេងៗសម្រាប់ព្យាបាល ថែទាំម្ចាស់មរតកនៅមុនពេលទទួលមរណភាពមិនបានយកមកពិចារណាផងទេ។ ម្យ៉ាងទៀត ដើមចោទដែលបានប្តឹងទាមទារមានចំនួន ៤ នាក់ប៉ុណ្ណោះ ហើយការដែលប្រគល់ភាគចំណែកនៃមរតកទៅអោយអ្នកដែលមិនបានប្តឹងទាមទារផងនោះ ក៏ជាការសម្រេចមិនត្រឹមត្រូវតាមបទបញ្ញត្តិនីតិវិធី នៃក្រមនីតិវិធីរដ្ឋប្បវេណីដែរ។

-<u>យល់ឃើញថា</u> : សាលដីការដ្ឋប្បវេណីលេខ ២០ "ក្រVIអ" ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្ដីមកនេះ មិនត្រឹមត្រូវទេ។

## ហេតុដូច្នេះ
## វិនិច្ឆ័យសេចក្ដី

១-ទទួលបណ្ដឹងសាទុក្ខលេខ ១៤៦ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៣ របស់ចុងចម្លើយឈ្មោះ [redacted] រ៉ម៉ាស់។

២-បដិសេធសាលដីការដ្ឋប្បវេណីលេខ ២០ "ក្រVIអ" ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ របស់សាលាឧទ្ធរណ៍។

៣-បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ១៧០ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៣ របស់តុលាការកំពូល ត្រឡប់ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ។

៤-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីដើមចោទ។

៥-សាលដីកានេះ ជំនុំជម្រះ នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៤។

| | | |
|---|---|---|
| -ឯកឧត្តម | [redacted] | ប្រធាន |
| -លោក | [redacted] | ចៅក្រម |
| -លោក | [redacted] | ចៅក្រម |
| -លោក | [redacted] | ចៅក្រម |
| -លោក | [redacted] | ចៅក្រម |
| -លោក | [redacted] | ក្រឡាបញ្ជី |

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម។
ភ្នំពេញ ថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១៤
ក្រឡាបញ្ជី
[redacted]

បានឃើញ
ភ្នំពេញ ថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១៤
ប្រធាន
[redacted]



Scanned with CamScanner